ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជាតិជំនួយសង្គម
NATIONAL SOCIAL ASSISTANCE FUND

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ
## សម្រាប់ខែមិថុនា ឆ្នាំ២០២៦

កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលការណ៍ណែនាំ ស្តីពី ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងបានចាប់ដំណើរការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ នៅខែមេសា ឆ្នាំ២០២៤។

**មូលនិធិជាតិជំនួយសង្គម** សរសេរជាអក្សរកាត់ថា **ម.ជ.ជ.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស គឺក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក៏ជាប្រតិបត្តិករទោលក្នុងការដឹកនាំអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។

តាមរយៈសេចក្តីជូនដំណឹងនេះ **មូលនិធិជាតិជំនួយសង្គម** មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ ការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែមិថុនា ឆ្នាំ២០២៦ ទទួលបានលទ្ធផល ដូចខាងក្រោម៖

| ចំនួនគ្រួសារទទួលបានប្រាក់ឧបត្ថម្ភ | មនុស្សវ័យចាស់អាយុពី៦០ឆ្នាំឡើង | ជនមានពិការភាព | ជនផ្ទុកមេរោគនិងជំងឺអេដស៍ | ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ (ករណី) | សិស្សានុសិស្ស | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| 781,775 | 429,164 | 67,994 | 6,874 | 43,929 | 425,280 | 53,760,266,000 |

*(ហាសិបបីប៊ីលាន ប្រាំពីររយហុកសិបលាន ពីររយហុកសិបប្រាំមួយពាន់រៀលគត់)*

បើគិតតាំងពីពេលចាប់ផ្តើមកម្មវិធីមក រដ្ឋបានចំណាយថវិកាសរុបចំនួន **១ ១៧១ ១១២ ១៣២ ០០០រៀល (មួយពាន់មួយរយចិតសិបមួយប៊ីលាន មួយរយដប់ពីរលាន មួយរយសាមសិបពីរពាន់រៀលគត់)** ស្មើនឹង **២៩២.៧៧ លានដុល្លារអាមេរិក**។

ព្រមជាមួយគ្នានេះ ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

- ចំពោះគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលមានបណ្ណសមធម៌មានសុពលភាព ហើយមិនទាន់បានចុះឈ្មោះចូលកម្មវិធី ឬ ទើបទទួលបានបណ្ណសមធម៌ថ្មី សូមអញ្ជើញទៅចុះឈ្មោះចូលកម្មវិធីនៅសាលាឃុំ សង្កាត់ណាមួយ ដើម្បីទទួលបានការឧបត្ថម្ភប្រចាំខែ ពីរាជរដ្ឋាភិបាល

- ចំពោះសិស្សានុសិស្សស្ថិតក្នុងគ្រួសារមានបណ្ណសមធម៌ សូមទៅបញ្ជាក់ការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធពីមន្ត្រីកម្មវិធីនៅសាលាដែលខ្លួនរៀន រួចបន្តទៅចុះឈ្មោះចូលកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ នៃក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នៅសាលាឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវបណ្ណសមធម៌មានសុពលភាព និងលិខិតបញ្ជាក់ចុះឈ្មោះចូលរៀន ដើម្បីទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី
- ការចុះឈ្មោះចូលកម្មវិធី ឬការបើកប្រាក់ឧបត្ថម្ភប្រចាំខែ គឺមិនមានការបង់ប្រាក់ ឬកាត់កម្រៃសេវានោះឡើយ
- សូមកុំចាញ់កលជនខិលខូចមួយចំនួន ដែលឃោសនាបោកប្រាស់ថា "បើគ្រួសារណាចង់បានបណ្ណសមធម៌ គឺត្រូវបង់ប្រាក់ទើបទទួលបាន" ដែលនេះគឺមិនត្រឹមត្រូវនោះឡើយ ព្រោះការទទួលបានបណ្ណសមធម៌ ត្រូវសម្ភាសតាមនីតិវិធីនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ ដោយមិនមានរើសអើងនិន្នាការនយោបាយ ឬយកកម្រៃនោះឡើយ
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីណាមួយពាក់ព័ន្ធទៅនឹងកម្មវិធី ឬមានការដាក់បញ្ចាំ ឬទទួលបញ្ចាំបណ្ណសមធម៌នោះ សូមរាយការណ៍ទៅអាជ្ញាធរឃុំ សង្កាត់ ឬ សាខាមូលនិធិជាតិជំនួយសង្គម ឬមន្ទីរផែនការរាជធានី ខេត្ត ឬ តាមរយៈ ប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ របស់មូលនិធិជាតិជំនួយសង្គម លេខ (០៩២ /០១៥) ២១៩ ៨៨៨ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
- ក្នុងករណីគ្រួសារទទួលផលមានចម្ងល់ ឬមានបញ្ហាពាក់ព័ន្ធទៅនឹងការបើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ សូមទំនាក់ទំនងទៅមន្ត្រីកម្មវិធីនៅសាលាឃុំ សង្កាត់ ឬ តាមរយៈ ប្រព័ន្ធទូរសព្ទទាន់ហេតុការណ៍ របស់មូលនិធិជាតិជំនួយសង្គម ដើម្បីជួយដោះស្រាយ
- រៀងរាល់ពេលបើកប្រាក់ឧបត្ថម្ភប្រចាំខែនៅតាមបញ្ជរវីង អ្នកទទួលផលត្រូវភ្ជាប់ទៅជាមួយនូវបណ្ណសមធម៌ច្បាប់ដើម និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- ករណីម្ចាស់គណនីទោលគ្រួសារមិនអាចបើកប្រាក់បាន សូមធ្វើការផ្ទេរសិទ្ធិទៅសមាជិកគ្រួសារណាម្នាក់ដែលមានអត្តសញ្ញាណបណ្ណ នៅសាលាឃុំ សង្កាត់ ដើម្បីបន្តការផ្តល់
- ស្នើដល់គ្រួសារទទួលផលទាំងអស់ប្រើប្រាស់ថវិកា ដែលទទួលបានពីកម្មវិធីឱ្យបានត្រឹមត្រូវ ចៀសវាងការប្រើប្រាស់ក្នុងការបម្រើឱ្យអបាយមុខផ្សេងៗ ដែលផ្ទុយពីឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានផ្តល់កិច្ចអន្តរាគមន៍ជំនួយសង្គមជាសាច់ប្រាក់នេះ។ ក្នុងករណីគេឃើញថាមានគ្រួសារទទួលផលដែលប្រើប្រាស់ខុសគោលដៅបែបនេះ អាជ្ញាធរមូលដ្ឋាននឹងធ្វើការអប់រំជាលាយលក្ខណ៍អក្សរ បើក្នុងករណីមិនរៀងចាល មេឃុំ ចៅសង្កាត់ អាចធ្វើការប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីធ្វើបច្ចុប្បន្នភាពបណ្ណសមធម៌នោះឡើងវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងស្ថាប័នពាក់ព័ន្ធ ពិសេស គ្រួសារមានបណ្ណសមធម៌ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តកម្មវិធីអាទិភាពរបស់រាជរដ្ឋាភិបាល ដែលកំពុងផ្តល់ការគាំពារដល់គ្រួសារក្រីក្រ និងសមាជិកគ្រួសារដែលមានភាពងាយរងគ្រោះ ក្នុងន័យ “ មិនទុកប្រជាជនណាម្នាក់ចោល ដោយមិនមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនោះឡើយ ”។

ថ្ងៃសុក្រ ៤ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាជាតិគាំពារសង្គម
- ក្រុមប្រឹក្សាភិបាល នៃមូលនិធិជាតិជំនួយសង្គម
- គ្រប់សាលារាជធានី ខេត្ត
- ធនាគារវីង (ខេមបូឌា) ម.ក
- ឯកសារ កាលប្បវត្តិ